# សេចក្តីថ្លែងគោលជំហរ និងធាតុចូលសំខាន់ៗ
# របស់ក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ
# លើការកសាងក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច
# និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់រៀបចំសេចក្តីព្រាងច្បាប់
# ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២

តាងនាមក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ ដែលសម្របសម្រួលដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា យើងខ្ញុំសូមសម្តែងនូវការកោតសរសើរ និងអបអរសាទរដល់រដ្ឋសភា និងរាជរដ្ឋាភិបាល ជាពិសេស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានខិតខំបំពេញភារកិច្ចប្រកបដោយ ការវិវត្តជាវិជ្ជមាននាពេលកន្លងមក ជាពិសេសក្នុងដំណាក់កាលនៃការរីករាតត្បាតនៃជំងឺកូវីដ ១៩ ជាអាទិ៍ ការងើបឡើងវិញនូវកំណើនសេដ្ឋកិច្ចពីជាងដក ៣% នៅឆ្នាំ២០២០ មកប្រមាណ ២,៤% ក្នុងឆ្នាំ២០២១នេះ និងការព្យាករណ៍កំណើនដល់ ៤,៨% នៅឆ្នាំ២០២២ខាងមុខនេះ ព្រមទាំងការសន្យាទទួលបានថវិកាជំនួយ ២៤០លានដុល្លារ ពីទុនបម្រុងទូទៅរបស់គណនីមូលនិធិពិសេស SDR ដែលក្រុមប្រឹក្សាភិបាលនៃមូលនិធិរូបិយវត្ថុអន្តរជាតិ(IMF)បានអនុម័តកាលពីដើមខែសីហានេះដើម្បីដោះស្រាយវិបត្តិកូវីដ១៩ និងស្តារសេដ្ឋកិច្ចឡើងវិញ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋសភាជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលតែងតែអញ្ជើញអង្គការសង្គមស៊ីវិល ចូលរួមនៅក្នុងកិច្ចប្រជុំនានា នាពេលកន្លងមក ព្រមទាំងបានបើកឱកាសនិងស្វាគមន៍នូវរាល់ការផ្តល់មតិយោបល់ធាតុចូល និងអនុសាសន៍ពីអ្នកពាក់ព័ន្ធនានា ដើម្បីធ្វើឲ្យក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច និងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ប្រកបដោយបរិយាប័ន្ន និងការគិតគូរខ្ពស់។ ក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិល (BWG) តែងតែយកចិត្តទុកដាក់លើការងារនេះជាប្រចាំ និងបានចូលរួមផ្តល់នូវមតិយោបល់ដែលជាឧត្តមប្រយោជន៍ដល់ប្រជាពលរដ្ឋ ជាមួយរដ្ឋសភាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាលើកិច្ចការដ៏មានសារៈសំខាន់នេះ។

ក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ សូមធ្វើការវាយតម្លៃខ្ពស់ចំពោះរាជរដ្ឋាភិបាល ជាពិសេសស្ថាប័ន ក្រសួងសាមី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានខិតខំប្រឹងប្រែងក្នុងការរៀបចំ និងផ្សព្វផ្សាយនូវរបាយការណ៍លទ្ធផលនៃការអនុវត្តថវិកាឆមាសទី១ និងការវាយតម្លៃការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ និងសេចក្តីព្រាងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់រៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២។

ក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិលជាតិនិងអន្តរជាតិ សូមអនុញ្ញាតលើកយកគោលជំហរធាតុចូលសំខាន់ៗ និងអនុសាសន៍ ដែលចេញមកពីការសិក្សាស្រាវជ្រាវ វិភាគនានារបស់ក្រុមការងារ ជូនដល់ រដ្ឋសភាជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចខាងក្រោម៖

ក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ សាទរចំពោះការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការបង្កើនចំណូលសរុបថវិការដ្ឋ ឬថវិកាជាតិ។ ទោះបីជាយ៉ាងណាសង្គមស៊ីវិលនៅតែមានការបារម្ភក្នុងការប្រមូលចំណូលសម្រេចទៅតាមផែនការ។ ដូចនេះសង្គមស៊ីវិលលើកទឹកចិត្តឱ្យរាជរដ្ឋាភិបាលគិតគូរឱ្យបានហ្មត់ចត់ក្នុងការធានាបាននូវការប្រមូលចំណូលនោះប្រកបដោយការទទួលខុសត្រូវខ្ពស់។ ចំណូល និងចំណាយ គឺត្រូវតែធ្វើឡើងឱ្យមានសមតុល្យគ្នា ព្រោះបើមិនដូច្នេះទេនឹងធ្វើឱ្យរដ្ឋាភិបាល បង្កើនការខ្ចី ពីបរទេសកាន់តែច្រើនថែមទៀត។

ក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិគាំទ្រចំពោះ បទអន្តរាគមន៍ទាក់ទងនឹងជំងឺកូវីដ ១៩ ក្នុងនោះក៏សូមស្នើរាជរដ្ឋាភិបាល ជាពិសេសក្រសួងសុខាភិបាល **ជួយគិតគូរបន្ថែមទៀតលើជំងឺមិនឆ្លង។**

ចំពោះការអភិវឌ្ឍសេដ្ឋកិច្ច សង្គមស៊ីវិលសូមស្នើ រាជរដ្ឋាភិបាល និងរដ្ឋសភា **ពិចារណាលើការវិភាជថវិកាសម្រាប់វិស័យអប់រំ និងបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈ គួរត្រូវបានបង្កើន លើសពីឆ្នាំមុនៗ** ដោយបង្កើត និងបង្កើនអន្តរកម្មរវាងវិស័យទាំងពីរនេះ ដើម្បីវិស័យនេះមានលទ្ធភាពបង្កើតកម្មវិធីសិក្សា និងវិធីសាស្ត្ររៀននិងបង្រៀនថ្មីៗឆ្លើយតបនឹងតម្រូវការលើកកម្ពស់ការត្រួតពិនិត្យវាយតម្លៃ និងផ្តល់កិច្ចគាំពារបច្ចេកទេសនានាបន្ថែម។

ក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ សូមស្នើ រាជរដ្ឋាភិបាល ធ្វើចំណាត់ថ្នាក់សម្រាប់ការប្រើប្រាស់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយតម្លាភាព និងមានប្រសិទ្ធភាពខ្ពស់ ជាពិសេសគួរផ្តោតលើការប្រើប្រាស់ថវិកាសម្រាប់ការអនុវត្តមុខងាររបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ(គ.ក.ស.ក) និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក) ក្នុងការផ្តល់សេវាសង្គមសម្រាប់ប្រជាពលរដ្ឋជាពិសេសស្ត្រី ជនមានពិការភាព និងកុមារ។ ការប្រើប្រាស់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ គួរផ្តោតលើការបំពេញមុខងាររបស់មន្ទីរជំនាញ ដែលបានទទួលការផ្ទេរមុខងារពីថ្នាក់ជាតិផងដែរ។ ជាមួយគ្នានេះ ការប្រើប្រាស់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិគួរផ្តល់អាទិភាពផងដែរ ចំពោះការអនុវត្តមុខងាររបស់សេវាច្រកចេញចូលតែមួយប្រកបដោយគុណភាព និងបែងចែកថវិកាសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមជំហានទី២ និងកម្មវិធីគណនេយ្យភាពសង្គមដំណាក់កាលទី២ ដោយជោគជ័យនិងពង្រឹងភាពជាម្ចាស់របស់រដ្ឋាភិបាល។ រដ្ឋាភិបាលគួរបង្កើនការចូលរួមរបស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលជាពិសេសជនដែលងាយរងគ្រោះនៅក្នុងដំណើររៀបចំផែនការ និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានប្រសើរឡើង និងធានាបាននូវគណនេយ្យភាពនៅក្នុងការផ្តល់នូវសេវាសាធារណៈ។ ជំរុញការអនុវត្តន៍គំនិតផ្តួចផ្តើម របស់រដ្ឋាភិបាលអេឡិចត្រូនិកដើម្បីធានាប្រសិទ្ធភាព នៃការផ្តល់សេវាសាធារណៈ សេវាសង្គម និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព នៃប្រទេសកម្ពុជា។

ក្នុងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច យើងខ្ញុំសូមស្នើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្យាករណ៍ឱ្យបានសុក្រិត ជៀសវាងការធ្វើនិយ័ត ឬវិចារណកម្មច្រើនដង។ ខាងក្រោមនេះគឺជាសេចក្តីស្នើលម្អិត៖

១. ការប្រមូលចំណូល៖ រដ្ឋគួរតែប្រមូលចំណូលឲ្យអស់លទ្ធភាព និងមានប្រសិទ្ធភាពខ្ពស់ ដោយឈរលើគោលការណ៍យុត្តិធម៌ និងសមធម៌ ដើម្បីរក្សាបាននូវស្ថេរភាពកំណើនសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ និងកាត់បន្ថយវិសមភាពសង្គម។ ជាផ្នែកមួយដើម្បីបង្កើនចំណូលជាតិបន្ថែមទៀត រដ្ឋាភិបាលគួរបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូលពន្ធលើអចលនទ្រព្យ។ យើងពិនិត្យឃើញថា ចំណូលពន្ធប្រចាំឆ្នាំលើអចលនទ្រព្យគឺមានត្រឹមតែ ០,១ ភាគរយ ប៉ុណ្ណោះនៃផលិតផលក្នុងស្រុកសរុប ដែលអត្រានេះទាបជាងប្រទេសដទៃទៀតជាច្រើន រួមទាំងប្រទេសនៅក្នុងតំបន់ផងដែរ។ រដ្ឋគួរបង្កើន ពន្ធអាករបន្ថែមលើផលិតផលដែលធ្វើឲ្យប៉ះពាល់ដល់សុខភាពដូចជា បារី គ្រឿងស្រវឹង និងភេសជ្ជៈប៉ូវកម្លាំង ហើយវិភាជទៅលើវិស័យសុខាភិបាល និងលុបចោលកម្មវិធីផ្សព្វផ្សាយគ្រឿងស្រវឹងគ្រប់រូបភាព និងអនុម័តច្បាប់គ្រប់គ្រងគ្រឿងស្រវឹងឲ្យបានឆាប់បំផុត ព្រោះគ្រោះថ្នាក់ចរាចរណ៍ និងការប្រើប្រាស់គ្រឿងស្រវឹងមានការកើនឡើងខ្លាំងគួរឲ្យព្រួយបារម្ភ ហើយបញ្ហានាំឲ្យវាខាតបង់សេដ្ឋកិច្ចជាតិច្រើនជាងចំណូលពី

ពន្ធពាក់ព័ន្ធនឹងគ្រឿងស្រវឹង និងការផ្សាយពាណិជ្ជកម្មដែលទទួលបានទៅទៀត បើយោងទៅតាមការស្រាវជ្រាវជាច្រើនដូចជានៅប្រទេសថៃជាដើម។

២. រាជរដ្ឋាភិបាលត្រូវត្រៀមខ្លួនឲ្យបានរួចរាល់ក្នុងការរៀបចំ និងស្តារនូវវិស័យដែលទ្រទ្រង់កំណើនសេដ្ឋកិច្ច ដូចជាវិស័យទេសចរណ៍ ដោយបន្ថែមនូវមុខងារឲ្យបានច្រើនដូចជា ទេសចរណ៍សិប្បនិមិត្ត ធម្មជាតិ និងវប្បធម៌ ជាដើម។ ចំពោះវិស័យកសិកម្ម ក្រសួងពាក់ព័ន្ធគួរមានយន្តការក្នុងការផលិតដើម្បីឲ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ជាពិសេសទីផ្សារសហគមន៍មូលដ្ឋានដែលក្នុងនោះ កសិឧស្សាហ៍កម្មគួរតែត្រូវបានយកចិត្តទុកដាក់ផងដែរ។ បន្តជំរុញការអភិវឌ្ឍវិស័យកសិកម្ម ដោយយកចិត្តទុកដាក់បន្ថែម និងលើកទឹកចិត្តប្រជាពលរដ្ឋផលិតស្បៀងអាហារប្រកបដោយសុវត្ថិភាព និងសុខុមាលភាព ព្រមទាំងគិតគូរដល់ការបង្កើនប្រព័ន្ធស្រោចស្រព និងចែកពូជដល់កសិករព្រមទាំងគាំទ្រថវិកាជាតិសម្រាប់ការផ្សព្វផ្សាយលើកកម្ពស់ពូជប្រពៃណី(ធម្មជាតិ)។

៣. ការចំណាយ៖ សូមស្នើរាជរដ្ឋាភិបាលយកចិត្តទុកដាក់ក្នុងការកាត់បន្ថយនូវចំណាយដែលមិនចាំបាច់ ឬត្រូវធានាថា រាល់ការចំណាយគឺឆ្លើយតប ទៅនឹងគោលនយោបាយដោយផ្តោតលើវិស័យអាទិភាពមួយចំនួន ដូចជាវិស័យសុខាភិបាល លើជំងឺឆ្លង និងជំងឺមិនឆ្លង។

៤. រាជរដ្ឋាភិបាលគួរផ្តោតសំខាន់លើវិស័យអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈដើម្បីឆ្លើយតបតម្រូវការអភិវឌ្ឍន៍ ជាពិសេសតម្រូវការទីផ្សារការងារ និងនវានុវត្តអប់រំប្រកបដោយបរិយាបន្ន ដោយធានាបាននូវបរិយាប័ន្នសង្គម ដូចជា ក) ពង្រឹងលើប្រព័ន្ធសុវត្ថិភាព និងកិច្ចគាំពារសង្គម ខ) កាត់បន្ថយការរំលោភបំពានសិទ្ធិស្ត្រី និងសិទ្ធិកុមារ ការរើសអើងនៃពិការភាព និងអត្តសញ្ញាណយេនឌ័រ។

៥. ពង្រឹងការឆ្លើយតបឲ្យមានប្រសិទ្ធភាពខ្ពស់ផ្នែកសុខាភិបាលទាំងនៅអំឡុងពេលនិងបន្ទាប់ពីបញ្ចប់ការរីករាលដាលនៃជំងឺកូវីដ-១៩ ក) ការលើកកម្ពស់ និងរក្សាឲ្យបាននូវបទដ្ឋានស្តង់ដារសុវត្ថិភាពអនាម័យ និងទឹកស្អាត នៅតាមសាលារៀន ខ) ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំនាញដែលឆ្លើយតបទីផ្សារនានាបច្ចុប្បន្ន សម្រាប់ការប្រកួតប្រជែងនាពេលអនាគត។

៦. វិនិយោគ និងបង្កើនការវិភាជចំណាយសាធារណៈទៅដល់វិស័យអប់រំ ដើម្បីធានាថាកុមារទាំងអស់ទទួលបានការរៀនសូត្រដែលមានគុណភាពល្អ ហើយដែលនេះស្របជាមួយនឹងការប្តេជ្ញាចិត្តរបស់ខ្លួននៅឯកិច្ចប្រជុំកំពូល នៃភាពជាដៃគូសម្រាប់ការអប់រំកាលពីឆ្នាំ២០១៨ ដែលត្រូវបង្កើនដល់ ២៣% នៃចំណាយជាតិសរុប។

៧. ធានាថា កុមារទាំងអស់អាចរៀនសូត្របាន នៅក្នុងអំឡុងពេលនៃការបិទសាលារៀន ជាពិសេស ការរៀនសូត្រពីចម្ងាយប្រកបដោយគុណភាព បរិយាប័ន្ន តម្លៃសមរម្យ ដើម្បីឱ្យកុមារគ្រប់រូបអាចរៀនសូត្របាន រាជរដ្ឋាភិបាលកម្ពុជា ក៏គប្បីពង្រឹងសមត្ថភាពរបស់គ្រូបង្រៀន ក្នុងការគាំទ្រដល់ការរៀនសូត្រពីចម្ងាយ រួមទាំងតាមរយៈការបណ្តុះបណ្តាល និងជំនួយសមស្របជាមួយនឹងការទទួលបានបច្ចេកវិទ្យាផងដែរ។ នៅក្នុងបរិបទកូវីដ-១៩នេះផងដែរ រាជរដ្ឋាភិបាលកម្ពុជាគប្បីអនុវត្តប្រកបដោយប្រសិទ្ធភាពនូវគោលការណ៍ណែនាំដែលមានស្រាប់របស់ខ្លួន ដើម្បីធានាថា កុមារទាំងអស់អាចវិលត្រលប់ទៅសាលារៀនវិញ នៅពេលដែលការវិលត្រលប់នេះ មានសុវត្ថិភាព។ បន្ថែមលើនេះ ប្រព័ន្ធភ្លើងសញ្ញាចរាចរណ៍ពាក់ព័ន្ធនឹងជំងឺកូវីដ-១៩ គប្បីត្រូវអនុវត្តដោយប្រុងប្រយ័ត្ន សម្រាប់ការបើកសាលារៀនឡើងវិញ។

៨. រៀបចំ និងអនុវត្តនូវយុទ្ធសាស្ត្រ និងផែនការបំប៉នការអប់រំនៅក្នុងបរិបទនៃជំងឺ កូវីដ-១៩ និងមានការប្តេជ្ញាចិត្តផ្តល់ហិរញ្ញប្បទានយ៉ាងពេញលេញចំពោះផែនការនេះ។ រាជរដ្ឋាភិបាលកម្ពុជាក៏គប្បីសម្រប

សម្រួលការលើកកម្ពស់ភាពជាដៃគូប្រកបដោយបរិយាប័ន្ន និងការគៀរគរធនធានពីសំណាក់អ្នកពាក់ព័ន្ធ ជាពិសេសអង្គការសង្គមស៊ីវិល ដើម្បីអនុវត្តផែនការនេះ។

៩. រាជរដ្ឋាភិបាល គួរបង្កើនការចំណាយប្រចាំឆ្នាំដែលផ្តោតទាំងស្រុងលើបញ្ហាប្រែប្រួលអាកាសធាតុ ដោយមូលហេតុថា បញ្ហាប្រឈមចម្បងបណ្តាលមកពីការប្រែប្រួលអាកាសធាតុកាន់តែបង្កហានិភ័យខ្ពស់ក្នុងកម្រិត៧%នៃការចំណាយសរុបលើការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ជាពិសេសគួរផ្តោតកាន់តែខ្លាំងលើសកម្មភាពកាត់បន្ថយការប្រែប្រួលអាកាសធាតុ ប្រកបដោយនិរន្តរភាពនិងសកម្មភាពបន្សាំជាក់លាក់។

១០. រាជរដ្ឋាភិបាល គួរផ្តល់ព័ត៌មានប្រចាំឆ្នាំទៀងទាត់មានលក្ខណៈសាមញ្ញ ដល់សាធារណៈជន ទាក់ទងនឹងផលប៉ះពាល់បណ្តាលមកពីការប្រែប្រួលអាកាសធាតុ ការបែងចែកថវិកាជាតិនិងការចំណាយរបស់ក្រសួងពាក់ព័ន្ធ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានផលប្រយោជន៍ដល់ការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។

១១. រាជរដ្ឋាភិបាល គួរបង្កឱកាស ឲ្យមានការផ្តល់ធាតុចូលប្រកបដោយបរិយាបន្ន ពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់ ទៅលើដំណើរការកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ជាពិសេសដើម្បីអនុញ្ញាតិឲ្យអង្គការមិនមែនរដ្ឋាភិបាលបានចូលរួមពិភាក្សា ក្នុងការពិគ្រោះយោបល់ ដើម្បីធ្វើសេចក្តីសម្រេចលើថវិការដ្ឋទាក់ទងនឹងបញ្ហាប្រែប្រួលអាកាសធាតុ។

១២. រដ្ឋាភិបាលគួរបង្កើនថវិកាដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (ថ្នាក់ឃុំ ថ្នាក់ស្រុក និងថ្នាក់ខេត្ត) ដើម្បីធ្វើសកម្មភាពជាក់លាក់ក្នុងការឆ្លើយតបនឹងបញ្ហាប្រែប្រួលអាកាសធាតុឲ្យបានទាន់ពេលវេលា។

១៣. ក្រសួងស្ថាប័នពាក់ព័ន្ធនានា គួរបង្កើនការយកចិត្តទុកដាក់បន្ថែមទៀតក្នុងការបញ្ជ្រៀបបញ្ហាយេនឌ័រជាលក្ខណៈប្រព័ន្ធក្នុងកម្មវិធីអភិវឌ្ឍន៍ និងផែនការសកម្មភាពក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។

១៤. រាជរដ្ឋាភិបាល គួរគិតគូរបន្ថែមលើការយកចិត្តទុកដាក់ពីផលប៉ះពាល់នៃជំងឺកូវីដ-១៩ទៅលើប្រជាពលរដ្ឋជាពិសេសអ្នកធ្វើការក្រៅប្រព័ន្ធ។ ជំរុញឱ្យមានផែនការច្បាស់លាស់ក្នុងការអភិវឌ្ឍធនធានមនុស្សផ្តោតលើជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ជាពិសេសក្នុងដំណាក់កាលនៃការរីករាតត្បាតនៃជំងឺកូវីដ ១៩ ដូចជាជម្រុញការបង្កើតនិងលើកកម្ពស់ការបង្រៀន និងរៀនតាមបែបឌីជីថល ជាដើម។

១៥. ការប៉ះពាល់ នៃការបាត់ការអនុគ្រោះពន្ធលើមុខទំនិញមួយចំនួន ក្នុងក្របខណ្ឌទំនិញគ្រប់បែបយ៉ាងលើកលែងសព្វាវុធ(EBA)ធ្វើឲ្យប៉ះពាល់ដល់វិស័យការងារនិងចំណូលរបស់ពលរដ្ឋដែលសង្គមស៊ីវិលសូមស្នើឲ្យរាជរដ្ឋាភិបាល ជំរុញឲ្យមានវិធានការឆ្លើយតបចំពោះកត្តាប្រឈម ដូចជាផ្តល់ប្រាក់ឧបត្ថម្ភបង្កើតការងារ គៀរគរកការវិនិយោគបន្ថែម។

១៦. រាជរដ្ឋាភិបាល គួរបន្តយកចិត្តទុកដាក់បន្ថែមទៀត លើប្រសិទ្ធភាពនៃការបែងចែកថវិកាថ្នាក់ក្រោមជាតិដោយសារមានការថយចុះ ដែលជាការព្រួយបារម្ភ ថាការអភិវឌ្ឍនៅមូលដ្ឋានភូមិ ឃុំ ស្រុកនឹងមានភាពយឺតយ៉ាវហើយគម្រោងវិនិយោគឃុំសង្កាត់មួយចំនួននឹងត្រូវពន្យារ ព្រមទាំងពង្រឹងនូវយន្តការចំណាយឲ្យមានប្រសិទ្ធភាព និងតម្លាភាព ដោយមានការចូលរួមពីប្រជាពលរដ្ឋមូលដ្ឋាន ស្របតាមគោលនយោបាយអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ (២០២១-២០៣០)។

១៧. ការបង្ហាញ និងការអប់រំសាធារណៈស្តីពីថវិកាប្រចាំឆ្នាំ ថវិកាជាតិនិងថ្នាក់ក្រោមជាតិមានកំរិត ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងនេះនៅគ្រប់កម្រិតនៃការបង្ហាញថវិកានិងលើកកម្ពស់កំណើនសេដ្ឋកិច្ចម៉ា

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អង្គការសង្គមស៊ីវិល អំពាវនាវឱ្យរាជរដ្ឋាភិបាល និងសភាអនុម័តច្បាប់ទទួលបានព័ត៌មាន ឱ្យបានឆាប់ តាមការជម្រុញរបស់សម្តេចនាយករដ្ឋមន្ត្រី ដែលនឹងត្រូវអនុម័តតាំងពីឆ្នាំ ២០២០មកម្លេះ។

១៨. រាជរដ្ឋាភិបាល គួរបន្តយកចិត្តទុកដាក់បន្ថែមទៀតក្នុងការធ្វើឱ្យប្រសើរឡើងនូវតម្លាភាពនៃការគ្រប់គ្រងថវិកាជាតិ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងលើកកម្ពស់គំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលអេឡិចត្រូនិក ដើម្បីធានាប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍន៍ប្រកបដោយចីរភាពសម្រាប់កម្ពុជា។

១៩. សូមស្នើរាជរដ្ឋាភិបាល ធ្វើការផ្សព្វផ្សាយនិងផ្តល់សេចក្តីព្រាងច្បាប់ថវិកាពេញលេញសម្រាប់ប្រជាពលរដ្ឋ និងបង្កើតឱ្យមានកិច្ចពិភាក្សា រវាង រដ្ឋសភា ក្រសួងស្ថាប័នរដ្ឋ ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល ដើម្បីបន្តចូលរួមចំណែកជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ក្នុងការពង្រឹងតម្លាភាពថវិកាដែលជាផ្នែកមួយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយបង្កើតយន្តការសាកល្បងដើម្បីចូលរួមជាសាធារណៈ ក្នុងអំឡុងពេលកសាងផែនការថវិកាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះដែររាជរដ្ឋាភិបាល គួរបង្កើតវេទិកា ឬយន្តការទៀងទាត់មួយសម្រាប់សាធារណជនចូលរួមវិភាគទានជាបដិមតិ ក្នុងន័យស្ថាបនាក្នុងដំណើរការត្រួតពិនិត្យការអនុវត្តថវិកា ដែលបានអនុម័តរួច។

២០. រៀបចំបង្កើតគម្រោងជំនួយផ្នែកច្បាប់ទូលំទូលាយមួយ ដែលមានការផ្តល់មូលនិធិប្រកបដោយចីរភាពរយៈពេលវែងពីថវិកាជាតិ និងបង្កើតតុលាការឧទ្ធរណ៍ថ្នាក់តំបន់ ក្រៅពីនៅរាជធានីឲ្យបានទូលំទូលាយ ដើម្បីធានាឲ្យទទួលបានតុលាការ និងសាលាជម្រះក្តីប្រកបដោយប្រសិទ្ធភាព ចំពោះស្ត្រីទាំងអស់ ជាពិសេស ស្ត្រីនៅតាមជនបទ ស្ត្រីជនជាតិដើមភាគតិច ស្ត្រីក្នុងក្រុមជាតិពិន្ទុភាគតិច និងស្ត្រីមានពិការភាព[1]។

២១. បែងចែកផ្តល់ថវិកា៣%នៃថវិកាជាតិសរុបសម្រាប់សកម្មភាពនានាក្នុងការលើកកម្ពស់សមភាពយេនឌ័រនៅគ្រប់ក្រសួង។ បែងចែកធនធាននិងមូលនិធិគ្រប់គ្រាន់ពីថវិកាជាតិ សម្រាប់ការអនុវត្តផែនការសកម្មភាពនិងគោលនយោបាយនានា សម្រាប់សមភាពយេនឌ័រ ដោយរួមទាំងផែនការយុទ្ធសាស្ត្រជាតិដើម្បីសមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចរបស់ស្ត្រី ("នារីរតនៈទីប្រាំ") ២០១៩ ដល់ ២០២៣)[2]។

២២. ព័ត៌មានអំពីកិច្ចលទ្ធកម្មសាធារណៈ ដែលស្ថិតនៅក្រោមការគ្រប់ដណ្តប់ នៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ជាពិសេសព័ត៌មានអំពីកិច្ចលទ្ធកម្មសម្រាប់ការអនុវត្តហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍គួរត្រូវបានផ្សព្វផ្សាយជាសាធារណៈកាន់តែទូលំទូលាយ។ ព័ត៌មានទាំងនោះរួមមាន៖ សេចក្តីជូនដំណឹងស្តីពីការដាក់ឱ្យដេញថ្លៃ រួមទាំងឯកសារលម្អិតដែលពាក់ព័ន្ធ កំណត់ហេតុបើកឯកសារដេញថ្លៃ កំណត់ហេតុវាយតម្លៃសំណើដេញថ្លៃ និងលិខិតប្រគល់កិច្ចសន្យាស្តីពីការផ្គត់ផ្គង់ជាដើម។ ជាងនេះទៅទៀត រដ្ឋាភិបាល គួរតម្រូវឱ្យក្រុមហ៊ុនដែលចូលរួមដាក់សំណើដេញថ្លៃ បង្ហាញព័ត៌មានអំពីម្ចាស់ភាគហ៊ុនទាំងអស់របស់ខ្លួន និងអ្នកទទួលផលចុងក្រោយ ដើម្បីឆ្លើយតបនឹងការប្តេជ្ញារបស់រដ្ឋាភិបាលក្នុងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងអំពើពុករលួយ(UNCAC)។

២៣. ទិដ្ឋភាពបំណុល និងកម្ចីបរទេស៖ ស្ថានភាពបំណុល៖ រដ្ឋាភិបាលត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍គន្លឹះចំនួន ៥ របស់ខ្លួន ដែលក្នុងនោះមានចំណុចមួយគឺ ការប្រើប្រាស់ឥណទានប្រកបដោយតម្លាភាព

[1] សេចក្តីសង្កេតសន្និដ្ឋាន ទៅលើរបាយការណ៍តាមកាលកំណត់លើកទី៦ សម្រាប់ប្រទេសកម្ពុជា ១១ (ក)

[2] សេចក្តីសង្កេតសន្និដ្ឋាន ទៅលើរបាយការណ៍តាមកាលកំណត់លើកទី៦ សម្រាប់ប្រទេសកម្ពុជា ១៥ (ខ)

គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពខ្ពស់បំផុត។ យ៉ាងណាសង្គមស៊ីវិលសូមស្នើ រាជរដ្ឋាភិបាលជាពិសេសគឺក្រសួងសេដ្ឋកិច្ច និងអ្នកត្រួតពិនិត្យការអនុវត្តគម្រោងយកចិត្តទុកដាក់បន្ថែមទៀតលើការអនុវត្តគម្រោងទាំងអស់ដោយស្មារតីមនសិការជាតិ។ សូមស្នើរាជរដ្ឋាភិបាលប្រើប្រាស់នូវកម្ចីនេះប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពដោយធានាឲ្យបាននូវការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ជាពិសេសទាក់ទងនឹងការពង្រឹងការងារលទ្ធកម្មសាធារណៈ។ កម្ចីបរទេសគួរតែផ្តល់អាទិភាពមិនត្រឹមតែលើរចនាសម្ព័ន្ធរូបវ័ន្តប៉ុណ្ណោះទេ តែគួរតែត្រូវពិចារណាផងដែរទៅលើការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ចសង្គមដូចជាការកសាងជំនាញវិជ្ជាជីវៈដល់កម្មករ និងពិពិធកម្មសេដ្ឋកិច្ច។ រាជរដ្ឋាភិបាលគួរពិភាក្សា និងស្នើសុំការពន្យាពេលសងដល់ធនាគារផ្សេងៗដែលរដ្ឋាភិបាលបានខ្ចី។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម រដ្ឋសភា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មេត្តាទទួលយកនូវធាតុចូលសំខាន់ៗរបស់អង្គការសង្គមស៊ីវិល ដើម្បីពិចារណា ដោយសេចក្តីអនុគ្រោះ។ ក្រុមការងារយើងខ្ញុំ ត្រៀមខ្លួនជាស្រេច ក្នុងការជួបពិភាក្សា ផ្លាស់ប្តូរមតិយោបល់ ក្នុងគោលបំណងចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសកម្ពុជា ឲ្យបានរីកចម្រើនឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

សូម មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពស់ខ្ពង់អំពីយើងខ្ញុំ។

ថ្ងៃចន្ទ ៧រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០២១

<u>ក្រុមការងារចវិកា នៃអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ</u>

១. វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា
២. អង្គការតម្លាភាពកម្ពុជា
៣. វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ
៤. អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
៥. អង្គការស្តារកម្ពុជា
៦. ក្រុមប្រឹក្សាយុវជនកម្ពុជា
៧. អង្គការអាក់សិនអេតកម្ពុជា
៨. អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន
៩. អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល
១០. គណកម្មការសម្របសម្រួលសកម្មភាពសុខភាព
១១. អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា
១២. អង្គការសម្ព័ន្ធគណនេយ្យភាពសង្គមកម្ពុជា
១៣. អង្គការអុកស្វាមកម្ពុជា
១៤. អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា
១៥. អង្គការសីលការ